## អនុក្រឹត្យ លេខ ៨៤ អនក្រ.បក
## ស្តីពី ដើមទុនធនាគារជាតិនៃកម្ពុជា

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា

-តាមសំណើទេសាភិបាលធនាគារជាតិនៃកម្ពុជា

### សំរេច

មាត្រា ១ .- កំណត់ដើមទុនរបស់ធនាគារជាតិនៃកម្ពុជា ចំនួន ១០០.០០០.០០០.០០០.០០រៀល (មួយរយពាន់លានរៀល) ។

មាត្រា ២ .-

ធនាគារជាតិនៃកម្ពុជា ត្រូវចាត់ចែងការចុះបញ្ជីកា ក្នុងតារាងតុល្យការរបស់ខ្លួនអោយបានគ្រប់ចំនួន ។

មាត្រា ៣ .-

ដើមទុនខាងលើនេះត្រូវបានចុះបញ្ជី និងកាន់កាប់ផ្តាច់មុខដោយរាជរដ្ឋាភិបាល និងមិនអាចផ្ទេរ ឬដាក់អោយជាប់ល័ក្ខខ័ណ្ឌអ្វីឡើយ ។

មាត្រា ៤ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០២ ខែ តុលា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
ហ៊ុន សែន

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសូមចុះហត្ថលេខា
ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

ទេសាភិបាលធនាគារជាតិនៃកម្ពុជា
ហត្ថលេខា
ជា ចាន់តូ